ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣ ✻ ៩៩៩

ក្រសួងធនធានទឹក និងឧតុនិយម
✻
លេខ 211 សហណ ធនឧ

# សេចក្តីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត និងតាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា : កាលពីម៉ោង 16 ម៉ 00 ថ្ងៃទី 22 ខែសីហា ឆ្នាំ 2011 មានប្រពន្ធ័សម្ពាធទាប ( ITCZ ) មួយបានកើតឡើងនៅភាគខាងជើងប្រទេសកម្ពុជា ។

មកដល់ថ្ងៃទី 25 ខែសីហា ឆ្នាំ 2011 ប្រពន្ធ័សម្ពាធទាប ( ITCZ ) នេះ បានរំកិលខ្លួនចុះមកភាគខាងត្បូង និងបានបង្កើនឥទ្ធិពលរបស់ខ្លួនមកលើព្រះរាជាណាចក្រកម្ពុជា ។

ចាប់ពីថ្ងៃទី 26 ដល់ថ្ងៃទី 28 ខែសីហា ឆ្នាំ 2011 ឥទ្ធិពលនៃប្រពន្ធ័សម្ពាធទាបនេះ អាចធ្វើឱ្យផ្ទៃកមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា មានតំបន់ភាគខាងត្បូង តំបន់ភាគនិរតី និងតំបន់មាត់សមុទ្រ មានភ្លៀងធ្លាក់ច្រើន ដែលអាចបង្កឱ្យមានជំនន់ទឹកភ្លៀងនៅតាមបណ្តារាជធានី-ខេត្ត មួយចំនួនដូចជា រាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កណ្តាល ខេត្តព្រះសីហនុ និងកំណាត់ផ្លូវជាតិលេខ 4 ។ ផ្ទៃសមុទ្រកម្ពុជាមានរលកខ្លាំង និងមានកំពស់ពី 1 ម៉ែត្រ ទៅ 2 ម៉ែត្រ ។

យោងតាមសភាពការណ៍ធាតុអាកាសខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តារាជធានី-ខេត្ត ដូចបានជម្រាបជូនខាងលើ ពិសេសបងប្អូនប្រជានេសាទសមុទ្រ សូម **បង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់** ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១*

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh